ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
15 / 05 / 2015
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/297

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ អង្គារ ទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥

## សវនាការលើភស្តុតាង - ថ្ងៃ ២៧៨

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Matthew J. McCARTHY**

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖, លោក អែម ហ៊ុយ, កញ្ញា ជា ស៊ីវហ៊ាង, លោក Matthew J. McCARTHY, កញ្ញា Marie-Jeanne SARDACHTI |
| ការិយាល័យសហព្រះរាជអាជ្ញា៖, លោក សេង លាង, លោក Vincent de Wilde d'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អារុណ, លោក លីវ សុវណ្ណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក វ៉េន ពៅ, លោកស្រី ទី ស្រីនណា, លោកស្រី ជេត វណ្ណលី |

| |
|---|
| សាក្សី/ដើមបណ្តឹង៖ ខឹម បឿន (2-TCW-979), លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុផ្ធារី |
| ផ្សេងៗ៖ កញ្ញា ពេជ ចរិយា, លោក Laurent SOULARD, កញ្ញាសំ មករា, លោក លឿង សូភក្ត័, លោក លី សុតុល្យ, កញ្ញា Aphra LEE |

| ពេលវេលាទូទៅរបស់តុលាការ៖ | | |
|---|---|---|
| ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០១ | បញ្ចប់ម៉ោង៖ ១៥.២៨ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១២ | បញ្ចប់ម៉ោង៖១០.៣២ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៣ | បញ្ចប់ម៉ោង៖ ១៣.៣៤ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៣ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៤៩ នាទី |

| កិច្ចដំណើរការនីតិវិធីផ្សេងទៀត | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០១ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៣ | ០៩.០៥ |
| ការតាំងសំណួរទៅសាក្សី ខឹម បឿន (2-TCW-979) | អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៦<br>០៩.៤២<br>១៤.០៩ | ០៩.៤២<br>១៤.០៩<br>១៥.២៧ |
| ការប្រកាសពីអវត្តមានរបស់ចៅក្រម FENZ នៅក្នុងសវនាការពេលរសៀល | អង្គជំនុំជម្រះ | ១៣.៣៣ | ១៣.៣៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និង អនុញ្ញាតឲ្យគាត់តាមដានកិច្ច ដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួន ស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅសាក្សី ខឹម បឿន (2-TCW-979)**

អង្គជំនុំជម្រះបានធ្វើការតាំងសំណួរបឋមមួយចំនួនទៅសាក្សី ខឹម បឿន (2-TCW-979)។ បន្ទាប់មក មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានធ្វើការតាំងសំណួរបន្ត។

**ការប្រកាសពីអវត្តមានរបស់ចៅក្រម FENZ នៅក្នុងសវនាការពេលរសៀល**

ប្រធានអង្គជំនុំជម្រះបានប្រកាសថា លោកស្រីចៅក្រម FENZ នឹងអវត្តមាន ចាប់ពីសវនាការពេលរសៀល ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ រហូតដល់ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៥។ អនុលោមតាមវិធាន ៧៩ នៃវិធានផ្ទៃក្នុង ប្រធានអង្គជំនុំជម្រះតែងតាំងចៅក្រម KAROPKIN ជំនួសចៅក្រម FENZ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5855 | D157.64 | 00270974-00270975; 00363655-00363655; 00789272-00789273 | Report on Neang Dam | P | 0027097400270975 | 00363655 | 00789272 00789273 |

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4164 | | 00079337-00079338; 00973147-00973154; 00937104-00937106 | Prison List of a Re-Education Office of Tram Kak District | P | 00079337 00079338 | 00974147 | 00937104 |
| E3/2012 | | 00082724-00082728; 00276593-00276597; 00797682-00797687 | Report on Admissions of Prisoners from Department 105 to Party | P | | | |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E319/12.3.2 | D118/242 | 00998722-00998767; 01057675-01057732 | Strictly Confidential Written Record of Interview of [REDACTED] | SC | N/A | 01057679 01057680 01057681 01057682 01057685 01057686 01057687 01057689 01057690 01057695 01057696 01057697 01057701 01057702 01057703 01057704 01057721 01057723 01057724 01057730 | N/A |
| E3/746 | D243/2.1.17 | 00064485-00064511; 00428289-00428307; 00611870-00611892 | CPK Magazine entitled: "The Revolutionary Flag", Issue 7, July 1978 | P | 0064504 0064505 | 00428304 00428305 | 00611886 |
| E3/2048 | | 00079087-00079099; 00276562-00276570; 00611658-00611667 | Report on enemy's actions for Tram Kak District Police | P | | | |

<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៥)
- សម្រេចតែងតាំងចៅក្រម KAROPKIN ដើម្បីជំនួសកន្លែងចៅក្រម FENZ រហូតដល់ពេលគាត់មានវត្តមានវិញ។ (១៣.៣៥)

- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ នឹងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥។ (១៥.២៨)

| **<u>កាលវេលាសវនាការបន្ត</u>** |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីទហ៊ាំង** **Matthew J. McCARTHY**